## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

រឿងព្រហ្មទណ្ឌ

ខ:១៧៣/២២.២.២០១១

សាលដីកា

ខ:៩៣ក្រIVអ/០៦.៥.២០១៣

### តាមនាមប្រជារាស្ត្រខ្មែរ
### សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ: ០៦ក្រ ចុះថ្ងៃទី០៨-២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៦.៥.២០១៣ ដែលមានសមាសភាព ដូចតទៅ៖

### សមាសភាពក្រុមប្រឹក្សា

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធាន |
| លោក | [redacted] | ចៅក្រមប្រឹក្សា |
| លោក | [redacted] | ចៅក្រមប្រឹក្សា |

### តំណាងមហាអយ្យការ

លោក[redacted]

### ក្រឡាបញ្ជីសវនាការ

លោកស្រី[redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ: ១៧៣ ចុះថ្ងៃទី ២២.២.២០១១ រវាង:

១-ជនជាប់ចោទ ឈ្មោះ: [redacted] ហៀង ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ: [redacted] (រ) ម្តាយឈ្មោះ: [redacted] (រ) ទោសពីមុនគ្មាន ។

-ឃាត់ខ្លួនថ្ងៃទី២២.០៦.២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨៨២ ត.ព្រ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ ។

-មេធាវី [redacted] វិបុល ការពារសិទ្ធិឲ្យជនជាប់ចោទ ។

២-ជនជាប់ចោទ ឈ្មោះ [redacted] វណ្ណៈ ហៅ ណាក់ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។

-ឃាត់ខ្លួននៅថ្ងៃទី២១.០៦.២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៨៨៣ ត.ព្រ.ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១០ ។

-ជាប់ចោទពីបទៈ ប្លន់ (វាយយកទូរស័ព្ទដៃ) ប្រព្រឹត្តនៅ ផ្លូវបេតុង មុខរោងចក្រកាត់ដេរសាំហាន់ ក្រុមទី១២ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ជនរងគ្រោះ ឈ្មោះ [redacted] យៀង ភេទស្រី អាយុ២១ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាងអ៊ុតសក់ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ។

<u>៦រឿងហេតុមានដូចតទៅ</u>

-កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១០ វេលាម៉ោង២០ និង៣០នាទីយប់ មានករណីវាយយកទូរស័ព្ទដៃមួយកើតឡើង នៅចំណុចផ្លូវបេតុង មុខរោងចក្រកាត់ដេរសាំហាន់ ក្រុម១២ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលបង្កឡើងដោយជនសង្ស័យ៤នាក់ ១.ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ២១ឆ្នាំ ២.ឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ២១ឆ្នាំ ៣.ឈ្មោះ [redacted] ភេទប្រុស ៤.ឈ្មោះ [redacted] ភេទប្រុស បានធ្វើសកម្មភាពចាប់ក្រៀកជនរងគ្រោះឈ្មោះ [redacted] យៀង ភេទស្រី ក្រោយពីយកទូរស័ព្ទដៃបានហើយ ក៏នាំគ្នាគេចខ្លួនបាត់អស់ ។ លុះមកដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ កំលាំងសមត្ថកិច្ចក៏ប្រទះឃើញជនសង្ស័យឈ្មោះ [redacted] វណ្ណៈ ក៏បាននាំខ្លួនមកសាកសួរ និងឈានទៅធ្វើការឃាត់ខ្លួនជនសង្ស័យម្នាក់ទៀតឈ្មោះ [redacted] ហៀង នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១០ ចំណែកបក្ខពួកឈ្មោះ ហាក់ និងឈ្មោះ សៀង រត់គេចខ្លួនបាត់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ ១៩២ "ក្រ១" ចុះថ្ងៃទី ០៩.១២.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១.ផ្តន្ទាទោសៈ

ក.ឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ

ខ.ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ៦ឆ្នាំ (ប្រាំមួយឆ្នាំ) ពីបទ ប្លន់ (វាយយកទូរស័ព្ទដៃ) ប្រព្រឹត្តនៅផ្លូវបេតុង មុខរោងចក្រកាត់ដេរសាំហាន់ ក្រុម១២ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១០ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២.ទុកសិទ្ធិឲ្យជនរងគ្រោះឈ្មោះ [redacted] យៀង ប្តឹងទាមទារសំណងជាក្រោយតាមច្បាប់ ។

៣.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃ ២៦ ខែវិច្ឆិកា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហៀង និងឈ្មោះ [redacted] វណ្ណៈ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះឈ្មោះ សុខ យៀង បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែ៩ ឆ្នាំ២០១២ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍. ចុះថ្ងៃទី២៥-១២-២០១២ ។

<u>នាពេលសវនាការៈ</u>

-ជនជាប់ចោទ ឈ្មោះ [redacted] ហៀង (អវត្តមាន)

-ជនជាប់ចោទ ឈ្មោះ អោក [redacted] ហៅ ណាក់ (អវត្តមាន)

-មេធាវី លោក [redacted] វិបុល ការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

-ជនរងគ្រោះ ឈ្មោះ [redacted] យៀង (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និងសង្ខេបរឿងជូនអង្គសវនាការ

-តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានស្តាប់របាយការណ៍ ក្រោយពីបានពិនិត្យសំណុំរឿងមក ឃើញថា មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទ ឈ្មោះ [redacted] ហៀង ដូចបទចោទប្រកាន់របស់សាលាដំបូង តាមចម្លើយសារភាពរបស់ជនជាប់ចោទ ឈ្មោះ [redacted] ហៀង,[redacted] វណ្ណៈ ឆ្លើយនៅនគរបាល ស៊ីសង្វាក់គ្នា ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted] ។

ឃើញថាសាលក្រមព្រហ្មទណ្ឌ លេខ ១៨២ "ក្រ១" ចុះថ្ងៃទី៩.១២.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវ សុំតម្កល់ទុកជាបានការ ។

-មេធាវី លោក [redacted] វិបុល ការពារសិទ្ធិឲ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានស្តាប់របាយការណ៍ ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន និងក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងមក ឃើញថា កូនក្តីខ្ញុំឈ្មោះ [redacted] ហៀង បានឆ្លើយសារភាពថា ឈ្មោះ [redacted] វណ្ណៈ ហៅ ណាក់ ជាអ្នកប្រព្រឹត្ត ចំណែកខ្លួនពិតជាចាយលុយនោះមែន ។

សំណូមពរៈ សុំប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សាមេត្តាពិចារណាលើរូបកូនក្តីខ្ញុំឡើងវិញ និងសុំបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង ។

-ក្រោយពីបានអានចម្លើយជនជាប់ចោទ ។

-ក្រោយពីបានអានចម្លើយដើមបណ្តឹង ។

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

-ក្រោយពីបានស្តាប់មេធាវីធ្វើសេចក្តីសន្និដ្ឋាន ។

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## <u>សាលាឧទ្ធរណ៍</u>

-យល់ឃើញថា ៖

១.បណ្តឹងឧទ្ធរណ៍លេខ ៩៤៧ ចុះថ្ងៃ ២៧.១២.២០១០ របស់ឈ្មោះ [redacted] ហៀង ជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

-មេធាវី[redacted]វិបុល ការពារសិទ្ធិអោយជនជាប់ចោទ ។

២.ជនជាប់ចោទ ឈ្មោះ [redacted] ហៀង ឆ្លើយសារភាពថា ថ្ងៃ១៩.៦.២០១០ ម៉ោង ២០ម៉ោ៣០នាទី ពួកខ្លួនមាន៤នាក់ ឈ្មោះ សៀង, ឈ្មោះ ហាក់, ឈ្មោះ [redacted] វណ្ណៈ និងរូបខ្លួន បានឆក់យកទូរស័ព្ទដៃពីនារីម្នាក់ដោយខ្លួនជាអ្នកខ្វេះយកពីដៃនារីនោះ ហើយយកទៅលក់បាន១៦ម៉ឺនរៀល ។

៣.សាលក្រមព្រហ្មទណ្ឌលេខ ១៨២ "ក្រ១" ចុះថ្ងៃ៩.១២.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

**ហេតុដូចនេះ វិនិច្ឆ័យសេចក្តី**

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៩៨៧ ចុះថ្ងៃ២៧.១២.២០១០ របស់ជនជាប់ចោទ ឈ្មោះ [redacted] ហៀង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨២ "ក្រ១" ចុះថ្ងៃ៩.១២.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤.សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខ មេធាវី [redacted] វិបុល ការពារសិទ្ធិជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ។

បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

<u>**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់**</u> ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី21 ខែ....៧....ឆ្នាំ២០១៥..
ក្រឡាបញ្ជី

[redacted]